ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

# សេចក្តីថ្លែងការណ៍

## របស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
## (គ.ជ.ប.ជ)

យើងខ្ញុំទាំងអស់គ្នា ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សូមគាំទ្រទាំងស្រុងចំពោះគំនិតផ្តួចផ្តើមប្រកបដោយឧត្តមគតិជាតិដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលរបស់ជាតិ និងច្បាប់ពាក់ព័ន្ធ ដើម្បីកំណត់ឲ្យថ្នាក់ដឹកនាំនៃស្ថាប័នកំពូលរបស់ជាតិ គឺនាយករដ្ឋមន្ត្រី ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា និងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវតែជាឥស្សរជនខ្មែរដែលមានសញ្ជាតិខ្មែរតែមួយគត់ ។ នេះពិតជាការផ្តួចផ្តើមដ៏មានសារសំខាន់ដែលតម្កល់ផលប្រយោជន៍ជាតិជាធំ និងជាការទទួលខុសត្រូវចំពោះជោគវាសនាអនាគតរបស់ប្រជាជន និងមាតុភូមិកម្ពុជា ដោយមិនរារែកចំពោះការដោះស្រាយបញ្ហាជាតិ និងដើម្បីការពារឧត្តមប្រយោជន៍ជាតិដោយមិនអនុញ្ញាតឲ្យមានការជ្រៀតជ្រែកពីបរទេស ដែលនាំឲ្យមានការបែកបាក់សាមគ្គីភាព ឯកភាពផ្ទៃក្នុងរបស់ជាតិ និងនាំឲ្យប្រទេសជាតិជួបគ្រោះមហន្តរាយជាថ្មីឡើយ ។ វិសោធនកម្មនេះ ពិតជានាំមកនូវអធិបតេយ្យភាព ឯករាជ្យភាពពេញលេញជូនជាតិ និងធ្វើឲ្យប្រជាពលរដ្ឋកម្ពុជា មានមោទនភាពចំពោះជាតិសាសន៍ខ្លួនកាន់តែខ្លាំងឡើង ។

ព្រមជាមួយគ្នានេះផងដែរ យើងខ្ញុំសូមគាំទ្រពេញទំហឹងចំពោះក្រសួងយុត្តិធម៌ ដែលបានប្រតិកម្មតាមផ្លូវច្បាប់ ដើម្បីស្វែងរកការពិត និងផ្តល់យុត្តិធម៌ ជូនប្រមុខដឹកនាំនៃរាជរដ្ឋាភិបាលកម្ពុជា ដែលទទួលរងការចោទប្រកាន់ដោយបំផ្លើសការពិតថាមានសញ្ជាតិពីរ ដើម្បីបង្ហាញអំពីភាពត្រឹមត្រូវរបស់ថ្នាក់ដឹកនាំកំពូលនៃព្រះរាជាណាចក្រកម្ពុជាផង និងដើម្បីវែកមុខដ៏អាក្រក់របស់ជនបរទេសមួយក្រុមដែលតែងព្យាយាមបំផ្លាញអធិបតេយ្យភាព និងកិត្យានុភាពរបស់ព្រះរាជាណាចក្រកម្ពុជាផង ។/.

ថ្ងៃសុក្រ ២កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ៨ខែតុលា ឆ្នាំ២០២១